GMAC
Garment Manufacturers Association in Cambodia

# សេចក្តីជូនដំណឹង

សមាគមរោងចក្រកាត់ដេរនៅកម្ពុជា មានកិត្តិយសជម្រាបជូនដល់បណ្តារោងចក្រសហគ្រាសដែលជាសមាជិកឲ្យបានជ្រាបថា៖ ច្បាប់ស្តីពីការងារត្រូវបានធ្វើវិសោធនកម្មមាត្រាមួយចំនួន ជាពិសេសមាត្រា ៨៩ ដោយបានធ្វើការកែប្រែពី "ប្រាក់បំណាច់បណ្តេញចេញ" ទៅជា "ប្រាក់បំណាច់អតីតភាពការងារ" ដែលត្រូវបានប្រកាសឲ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/០៦១៨/០១០ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨។

ទោះបីជាច្បាប់វិសោធនកម្មខាងលើត្រូវបានប្រកាសឲ្យប្រើប្រាស់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈពុំទាន់បានចេញប្រកាសដើម្បីកំណត់ពីវិសាលភាព និងបែបបទនៃការអនុវត្តប្រាក់បំណាច់អតីតភាពការងារនេះនៅឡើយ។ សមាគមរោងចក្រកាត់ដេរនៅកម្ពុជាបាននិងកំពុងធ្វើការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងការផ្តល់ធាតុចូលជូនក្រសួង ដើម្បីកំណត់វិសាលភាព និងបែបបទនៃការអនុវត្តក៏ដូចជាកាលបរិច្ឆេទនៃការអនុវត្តច្បាប់វិសោធនកម្មនេះ។

អាស្រ័យដូចជម្រាបជូនខាងលើសមាគមរោងចក្រកាត់ដេរនៅកម្ពុជា សូមអំពាវនាវដល់សមាជិកទាំងអស់មេត្តារក្សាភាពស្ងៀមស្ងាត់ និងរង់ចាំដោយភាពអត់ធ្មត់ រហូតដល់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចេញប្រកាសកំណត់ពីវិសាលភាព និងបែបបទនៃការអនុវត្តប្រាក់បំណាច់អតីតភាពការងារនេះ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៨
សមាគមរោងចក្រកាត់ដេរនៅកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា GARMENT MANUFACTURERS ASSOCIATION IN CAMBODIA សមាគមកាត់ដេរនៅកម្ពុជា



តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ភូមិត្រពាំងគល់ សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Phnom Penh Special Economic Zone, Trapeang Kul Village, Sangkat Kantouk, Khan Por Sen Chey, Phnom Penh Cambodia.
Tel: (855) 23-88 34 35 E-mail: info@gmac-cambodia.org Website: www.gmac-cambodia.org